ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២៤







**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** «ផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់រយៈពេល ប្រាំឆ្នាំ ឆ្នាំ២០២៤ -២០២៨» ដែលត្រូវបានរៀបចំឡើងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រោមការសម្របសម្រួលដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ព្រហស្បតិ៍ ទី០១ ខែសីហា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអនុប្រធាន ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធាន ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួងស្ថាប័ន ជាសមាជិកទាំង ២២ និងអង្គភាពចំណុះ ឯកឧត្តម លោកជំទាវ អភិបាលរាជធានីខេត្ត ជាប្រធានគណៈកម្មាធិការរាជធានីខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងអង្គទូតនានានៃបណ្តាប្រទេស ពាក់ព័ន្ធ មាននិវេសនដ្ឋាន ក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការដៃគូ ភ្ញៀវជាតិ អន្តរជាតិ សរុបប្រមាណ ជិត ៤០០នាក់ ។

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានកសាងឡើង ដោយមានការពិគ្រោះយោបល់ជាច្រើនលើក ច្រើនសារជាមួយថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ យោងតាមការវាយតម្លៃផែនការ ឆ្នាំ២០១៩-២០២៣ ដែលទើបនឹងបញ្ចប់ទៅ ស្ថានភាពប្រែប្រួលជាសាកល ការប្រែប្រួលនៃបទល្មើស និងបណ្តាញជនល្មើស និងប៉ាន់ប្រមាណពីភាពប្រឈម នឹងចំណុចខ្វះចន្លោះ ចំពោះមុខ និងត្រូវដាក់វិធានការដោះស្រាយបន្ត ។

យុទ្ធសាស្ត្រគន្លឹះ ចំនួនបួន ត្រូវបានកំណត់យ៉ាងជាក់លាក់អំពីភាពប្រទាក់ក្រឡា ដែល មិនមានក្រសួង
ស្ថាប័នណា ឬវិស័យណា ចៀសផុតពីការទទួលខុសត្រូវឡើយ។ យុទ្ធសាស្ត្រទាំងបួនគឺ៖
យុទ្ធសាស្ត្រទី១ គឺ លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ
យុទ្ធសាស្ត្រទី២ គឺ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់
យុទ្ធសាស្ត្រទី៣ គឺ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារ និងការផ្តល់សេវាជូនជនរងគ្រោះ
និង យុទ្ធសាស្ត្រទី៤ គឺជាស្នូលនៃយុទ្ធសាស្ត្រទាំងបី ដែលជាភាពចាំបាច់ត្រូវអនុវត្ត នៅគ្រប់យុទ្ធសាស្ត្រ គឺ ការពង្រឹងកិច្ចសហប្រតិបត្តិការ ការកងសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ។

ការតាមដាន វាយតម្លៃ រាយការណ៍ ចងក្រង និងផ្សព្វផ្សាយពីបទពិសោធន៍ ដើម្បីបង្កើនប្រសិទ្ធភាព នឹងត្រូវបានធ្វើជាប្រចាំផងដែរ។
ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គណៈកម្មាធិការជាតិ បានដាស់តឿន ក្រើនរំលឹក ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ក្នុងគណៈកម្មាធិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាអ្នកពាក់ព័ន្ធ គប្បីខិតខំបន្ថែមទៀត អនុវត្តឲ្យបានជោគជ័យ តាមការរំពឹងទុក ក្នុងផែនការ ប្រាំឆ្នាំនេះ ប្រកបដោយឆន្ទៈ និងការទទួលខុសត្រូវ ព្រោះរាជរដ្ឋាភិបាល បានចាត់ទុក ការងារប្រឆាំងការជួញដូរមនុស្ស ជាអាទិភាពខ្ពស់បំផុត ដូចការប្រឆាំងគ្រឿងញៀន និងចរាចរណ៍ផ្លូវគោកដែរ ៕









